# ៣-នមស្សការ ព្រះរតនត្រ័យ

(ធម៌ ជា បាលី និង ពន្យល់ន័យ)

**-នមោ** ខ្ញុំសូមគោរព,

**-តស្ស** ព្រះអង្គនោះ.

**-ភគវតោ** ចំពោះព្រះមានព្រះភាគ គឺជាព្រះអង្គលោកមានមេត្តាចែកភាគចំណែកធម៌មកឲ្យយើង,

**-អរហតោ** ព្រះអង្គជាព្រះអរហន្ត គឺថា: ព្រះអង្គឆ្ងាយចាកកិលេស អស់គ្រឿងប្រឡាក់ពី ក្នុងព្រះទ័យព្រះអង្គហើយ.

**-សម្មាសម្ពុទ្ធស្ស** ព្រះអង្គ ត្រាស់ដឹង ដោយព្រះអង្គឯង ដ៏ប្រពៃ។

បើនិយាយរួម **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** គឺថា :

ខ្ញុំសូមគោរព ព្រះពុទ្ធ ដែលមានគុណ ៣ប្រការ ដោយសង្ខេប គឺ :

១-ភគវតោ : ចែកធម៌ដល់អ្នកដទៃ (**ជាករុណាគុណ**),

២-អរហតោ : ជាព្រះអរហន្ត ព្រះអង្គ អស់កិលេស ជា អ្នកមានសេចក្ដីស្អាតបរិសុទ្ធ (**ជាវិសុទ្ធិគុណ**),

៣-សម្មាសម្ពុទ្ធស្ស : ព្រះអង្គ ត្រាស់ដឹងដោយខ្លួនព្រះអង្គ ដ៏ប្រពៃ បានន័យថា ព្រះអង្គ មានប្រាជ្ញាល្អណាស់ (**ជាបញ្ញាគុណ**)។

រួមសេចក្ដីទៅ យើងថ្វាយបង្គំ ព្រះពុទ្ធ គឺនឹកដល់ គុណទាំង ៣ ខាងលើនេះ ។

វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ " ← " ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។